ឧត្តមស្នងការរងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ

# លោកស្រី ហ្លាវា ផាន់សៀរី បញ្ចប់ដំណើរទស្សនកិច្ចនៅប្រទេសកម្ពុជា

**ភ្នំពេញ ថ្ងៃទី ២ ខែឧសភា ឆ្នាំ២០១៤**

សួស្តីលោក លោកស្រី និង សូមអរគុណដែលបានអញ្ជើញមក។

ខ្ញុំជិតបញ្ចប់ដំណើរទស្សនកិច្ចលើកដំបូងរបស់ខ្ញុំនៅប្រទេសកម្ពុជា ក្នុងឋានៈជាឧត្តមស្នងការរងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។

នៅក្នុងអំឡុងពេលដំណើរទស្សនកិច្ចរយៈពេល ៥ថ្ងៃ របស់ខ្ញុំ ខ្ញុំបានជួបជាមួយសមភាគីពីរាជរដ្ឋាភិបាល ក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស និង សហគមន៍ទូត ក៏ដូចជាសង្គមស៊ីវិល។ ដំណើរទស្សនកិច្ច នេះអាចឲ្យខ្ញុំបានពិនិត្យមើលស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ដែលជាផ្នែកនៃការរីកចម្រើន និង ឱកាសសម្រាប់ការធ្វើឲ្យប្រសើរឡើង។

នៅក្នុងបរិបទនេះ ខ្ញុំបានជួបប្រជុំប្រកបដោយស្ថាបនាជាមួយឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ឯកឧត្តម ឱម យិនទៀង ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ព្រមទាំងជាមួយអាជ្ញាធរផ្សេងទៀត។

ជាទម្លាប់ នៅពេលចុងបញ្ចប់នៃការបំពេញបេសកកម្មផ្លូវការ ដូចជាបេសកកម្មលើកនេះដែរ ខ្ញុំសូមធ្វើការកត់សំគាល់ និង ផ្តល់អនុសាសន៍មួយចំនួនទាក់ទងនឹងស្ថានភាពសិទ្ធិមនុស្សបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា។

## សេរីភាពនៃការបញ្ចេញមតិ និង ការជួបជុំដោយសន្តិវិធី

ប្រទេសកម្ពុជា ត្រូវបានកោតសរសើរថាជាប្រទេសដែលមានការបញ្ចេញមតិដោយសេរី ដែលគេមើលឃើញនៅក្នុងឆមាសទីពីរនៃឆ្នាំមុន ដែលជាទូទៅ អាជ្ញាធរបានសំដែងនូវអាកប្បកិរិយាវិជ្ជមានចំពោះការប្រមូលផ្តុំរបស់សាធារណជន។ សេរីភាពនៃការបញ្ចេញមតិ និង ការជួបជុំដោយសន្តិវិធី គឺជាធាតុសំខាន់សម្រាប់លទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា និង សម្រាប់ពិភាក្សា និងដោះស្រាយបញ្ហានយោបាយ។

ប៉ុន្តែ ខ្ញុំមានការសោកស្តាយជាខ្លាំងចំពោះហេតុការណ៍ដែលបណ្តាលឲ្យមានការបាត់បង់ជីវិតមនុស្សយ៉ាងហោចណាស់ចំនួនប្រាំមួយនាក់ នៅចន្លោះខែកញ្ញា ឆ្នាំ ២០១៣ និង ខែមករា ឆ្នាំ ២០១៤ ព្រមទាំងការបាត់ខ្លួនក្មេងអាយុ ១៦ ឆ្នាំ ឈ្មោះ ខឹម សម្បត្តិ។ របាយការណ៍ស៊ើបអង្កេតស្តីពី ការស្លាប់មនុស្សពុំទាន់ត្រូវបានផ្សព្វផ្សាយ ហើយមកដល់ពេលនេះ គ្មានអ្នកណាម្នាក់ត្រូវបានឲ្យទទួលខុសត្រូវនៅឡើយ។ ខ្ញុំសូមអំពាវនាវដល់អាជ្ញាធរខិតខំចាប់ជនល្មើសមកកាត់ទោសដោយគ្មានការយឺតយ៉ាវឡើយ។

ខ្ញុំមានការក្រៀមក្រំយ៉ាងក្រៃលែងដោយដឹងថា កាលពីម្សិលមិញ មានការវាយដំទៅលើបុរសម្នាក់នៅទីលានប្រជាធិបតេយ្យ ក្នុងរាជធានីភ្នំពេញ ពីសំណាក់ក្រុមសន្តិសុខខណ្ឌ។ ខ្ញុំក៏មានការព្រួយបារម្ភផងដែរ ដោយដឹងថា មានអ្នកសារព័ត៌មានមួយចំនួនត្រូវបានវាយដំពីសំណាក់ក្រុមសន្តិសុខនៅពេលពួកគេកំពុងព្យាយាមថតរូប ។ ការប្រើប្រាស់កម្លាំងហួសហេតុនាំឲ្យមានការព្រួយបារម្ភយ៉ាងខ្លាំងពីតួនាទីរបស់ក្រុមសន្តិសុខខណ្ឌ ក្នុងការដោះស្រាយរឿងបាតុកម្ម និង សណ្តាប់ធ្នាប់សាធារណៈ។

ខ្ញុំមានការសោកស្តាយដែលបានវាយតម្លៃថា វាមានភាពកាន់តែធ្ងន់ធ្ងរទៅនៅក្នុងឆ្នាំ ២០១៤ នៅក្នុងកម្រិតមួយដែលសេរីភាពនៃការបញ្ចេញមតិ និង ការជួបជុំនៅក្នុងប្រទេសកម្ពុជាត្រូវបានធានា និងទទួលបាន។ បម្រាមមិនឲ្យធ្វើបាតុកម្មនៅរាជធានីភ្នំពេញ ដែលបានចូលជាធរមានចាប់តាំងពីថ្ងៃទី ៤ ខែ មករា គឺជាបញ្ហាដែលខ្ញុំបានលើកឡើងជាមួយអាជ្ញាធរក្នុងឱកាសជាច្រើននៅក្នុងសប្តាហ៍នេះ។ ដោយរំលឹកពីកាតព្វកិច្ចរបស់រដ្ឋតាមកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយក្នុងការប្រកាន់ខ្ជាប់ទៅនឹងសិទ្ធិសេរីភាពបញ្ចេញមតិ ការជួបប្រជុំដោយសន្តិវិធី និង ការបង្កើតសមាគម ខ្ញុំសូមបញ្ជាក់ពីទស្សនៈរបស់ខ្ញុំថា បម្រាមមិនឲ្យធ្វើបាតុកម្មពុំមានការធ្វើតេស្តន៍អំពីនីត្យានុកូលភាព ភាពចាំបាច់ និង សមាមាត្រទេ។ ខ្ញុំសូមជំរុញឲ្យរដ្ឋាភិបាលចាត់វិធានការចាំបាច់ដើម្បីដកបម្រាមនេះចេញដោយគ្មានការយឺតយ៉ាវទៀតឡើយ និងដើម្បីធានាថា ប្រជាពលរដ្ឋទាំងអស់អាចអនុវត្តសិទ្ធិសេរីភាពបញ្ចេញមតិ និង ការជួបជុំរបស់គេបាន។

នៅក្នុងអំឡុងពេលដំណើរទស្សនកិច្ចរបស់ខ្ញុំ ខ្ញុំមានឱកាសជួបពិភាក្សាជាមួយតំណាងមកពីសង្គមស៊ីវិលដ៏រស់រវើក និងផ្សេងៗគ្នារបស់ប្រទេសកម្ពុជា ក្នុងនោះរួមមានអង្គការក្រៅរដ្ឋាភិបាល សមាគម សហជីព និង ស្ថាប័នផ្សេងទៀត ដែលបន្តរួមចំណែកដ៏មានតម្លៃចំពោះការអភិវឌ្ឍ និង ប្រជាធិបតេយ្យនីយកម្មរបស់ប្រទេសកម្ពុជា។ ខ្ញុំបានទទួលដំណឹងពីសេចក្តីព្រាងច្បាប់មួយចំនួនដែលសង្គមស៊ីវិលបារម្ភថា អាចដាក់កាតព្វកិច្ចទៅលើអង្គការក្រៅរដ្ឋាភិបាល សមាគម និង សហជីព និង អាចធ្វើខូចដល់ដំណើរការប្រជាធិបតេយ្យ ដែលស្ថាប័នទាំងនេះធ្វើប្រតិបត្តិការ។ សេចក្តីព្រាងច្បាប់

ទាំងនេះ រួមមានសេចក្តីព្រាងច្បាប់ស្តីពីសមាគម និង អង្គការក្រៅរដ្ឋាភិបាល សេចក្តីព្រាងច្បាប់ស្តីពីសហជីព និង សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធ័រណិត ដែលធ្វើការរឹតត្បិតមិនត្រឹមត្រូវដល់សេរីភាពតាមប្រព័ន្ធអេឡិកត្រូនិចរបស់ពលរដ្ឋកម្ពុជាទាំងអស់។ រដ្ឋាភិបាលគួរធានាថា វិធានការច្បាប់ណាមួយដែលមានបំណងគ្រប់គ្រងប្រតិបត្តិការរបស់អង្គការក្រៅរដ្ឋាភិបាល សមាគម និង សហជីព ក៏ដូចជាសកម្មភាពតាមប្រព័ន្ធអេឡិកត្រូនិច គោរពតាមបទដ្ឋានអន្តរជាតិសម្រាប់សេរីភាពបញ្ចេញមតិ និង បង្កើតសមាគម ដូចបានធានាដោយកតិកាសញ្ញានេះ។

## នីតិរដ្ឋ

កំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ នៅតែជាចំណុចសំខាន់សម្រាប់កិច្ចខិតខំប្រឹងប្រែងដើម្បីធានានីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំបានទទួលដំណឹងថា ច្បាប់មូលដ្ឋានបីស្តីពីប្រព័ន្ធតុលាការនឹងត្រូវអនុម័តក្នុងពេលណាមួយឆាប់ៗនេះ។ ច្បាប់ទាំងនេះមានសារៈសំខាន់ណាស់ក្នុងការលើកកម្ពស់ និង ការពារឯករាជ្យភាពនៃប្រព័ន្ធតុលាការ និង ធ្វើឲ្យប្រសើរឡើងនូវរដ្ឋបាលយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា។

ខ្ញុំយល់ឃើញថា រដ្ឋាភិបាលចង់ឃើញច្បាប់ទាំងនេះត្រូវបានអនុម័តឆាប់ៗតាមដែលអាចធ្វើទៅបាន។ នៅក្នុងពេលជាមួយគ្នានេះដែរ វាមានសារៈសំខាន់ដែលថា ច្បាប់ទាំងនេះដាក់ឲ្យពិគ្រោះយោបល់ទូលំទូលាយជាមួយភាគីពាក់ព័ន្ធទាំងអស់ ហើយដាក់ឲ្យចូលជាធរមានបាន តែពេលណាដែលច្បាប់ទាំងនេះស្របទៅនឹងបទដ្ឋានអន្តរជាតិប៉ុណ្ណោះ។ ជាងនេះទៀត ខ្ញុំមានជំនឿយ៉ាងមុតមាំថា វាជាផលប្រយោជន៍របស់រដ្ឋាភិបាលក្នុងការធ្វើឲ្យភាគីពាក់ព័ន្ធ ចូលរួមក្នុងការរៀបចំសេចក្តីព្រាងច្បាប់ដើម្បីធានាថា ដំណើរការនេះទទួលប្រយោជន៍ពីយោបល់របស់អ្នកជំនាញការទាំងអស់ ដែលពួកគេអាចចូលរួមបាន។ តាមបទពិសោធន៍របស់ពួកយើង ការចូលរួមពីសាធារណជននៅក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ ជួយធ្វើឲ្យប្រសើរឡើងនូវគុណភាពសេចក្តីព្រាងច្បាប់ លើកកម្ពស់ការគ្រប់គ្រង និងសម្រួលដល់ការអនុវត្តបន្ទាប់ពីច្បាប់ត្រូវបានអនុម័ត។

ខ្ញុំបានជួបជាមួយប្រធានសាលាឧទ្ធរណ៍ និង មានការរីករាយដែលបានទទួលដំណឹងពីការរីកចម្រើនមកដល់សព្វថ្ងៃក្នុងការធ្វើឲ្យប្រសើរឡើងដល់តុលាការ និង ការគ្រប់គ្រងសំណុំរឿង នៅសាលាឧទ្ធរណ៍ ព្រមទាំងសហប្រតិបត្តិការរវាងតុលាការ និងពន្ធនាគារ។ កិច្ចខិតខំប្រឹងប្រែងនេះបានជួយរួចហើយដល់ការកាត់បន្ថយការកកស្ទះសំណុំរឿងបណ្តឹងឧទ្ធរណ៍បានយ៉ាងច្រើនសន្ធឹកសន្ធាប់។

ឯករាជ្យភាព តម្លាភាព និង ការផ្តល់ធនធានគ្រប់គ្រាន់ដល់ប្រព័ន្ធតុលាការ មានសារៈសំខាន់ ដើម្បីឲ្យប្រជាពលរដ្ឋមានលទ្ធភាពទទួលបាននូវដំណោះស្រាយដែលមានប្រសិទ្ធភាព ប្រសិនបើ សិទ្ធិរបស់គេត្រូវបានរងនូវការរំលោភបំពាន។

ខ្ញុំបានមានឱកាសជួបជាមួយមន្ត្រីអ.វ.ត.ក ដើម្បីទទួលដំណឹងបន្ថែមពីការរីកចម្រើននៅក្នុងដំណើរការកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលបានប្រព្រឹត្តឡើងក្នុងរបបខ្មែរក្រហម។ អ្វីដែលកំពុងកើតឡើងនៅ អ.វ.ត.កនោះ គឺថាវាមានសារៈសំខាន់ជាប្រវត្តិសាស្ត្រ។ ទោះបីជាមានការប្រឈមទាំងអស់យ៉ាងណាក៏ដោយ យុត្តិធម៌ត្រូវតែរកឃើញ។ ប្រជាពលរដ្ឋកម្ពុជា ទាំងចាស់ ទាំងក្មេង សង្ឃឹមបែបនេះ ហើយយើងត្រូវតែបន្តគាំទ្រដល់ដំណើរការនេះ។ ខ្ញុំមានការរីករាយដែលបានទទួលដំណឹងថា ការអនុវត្តល្អមួយចំនួននៅអ.វ.ត.ក កំពុងយកមកអនុវត្តក្នុងប្រព័ន្ធតុលាការជាតិរួចហើយ។

ក្នុងអំឡុងពេលទស្សនកិច្ចនេះ ខ្ញុំមានការរីករាយដែលមានឱកាសបានជួបជាមួយអង្គការ TPO ជាអង្គការដែលជួយដល់អ្នកទទួលរងការប៉ះពាល់សុខភាពផ្លូវចិត្តធ្ងន់ធ្ងរពីភាពព្រៃផ្សៃដែលបានប្រព្រឹត្តដោយរបបខ្មែរក្រហម។ ខ្ញុំមានការចាប់អារម្មណ៍ជាខ្លាំងលើ ការប្តេជ្ញាចិត្ត និង ការលះបង់របស់បុគ្គលិក។ ខ្ញុំក៏យល់ឃើញថាមានសារៈសំខាន់ក្នុងការបន្តជួយជនរងគ្រោះ គឺថា ខ្ញុំមានសេចក្តីរីករាយ ដែលអង្គការសហប្រជាជាតិ អាចជួយដោយផ្ទាល់ដល់ជនរងគ្រោះតាមរយៈមូលនិធិស្ម័គ្រចិត្តអង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះដោយអំពើទារុណកម្ម។

## កំណែទម្រង់ពន្ធនាគារ

កាលពីព្រឹកមិញនេះ ខ្ញុំបានធ្វើទស្សនកិច្ចទៅកាន់មជ្ឈមណ្ឌលអប់រំកែប្រែទី១ (CC1) និងបានសម្ភាសន៍ លោក វ៉ន ពៅ ដែលកំពុងជាប់ឃុំឃាំងជាបណ្តោះអាសន្នរង់ចាំសវនាការ ពីបទចោទប្រកាន់ទាក់ទងនឹងព្រឹត្តិការណ៍ថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ និងបានសម្ភាសន៍ លោក ង្វៀង ធីដុក ដែលត្រូវបានផ្តន្ទាទោសពីបទចោទប្រកាន់ទាក់ទងនឹងព្រឹត្តិការណ៍នៅស្ពានក្បាលថ្នល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០១៣ និង លោក វណ្ណី វ៉ាណន ដែលប្រឈមនឹងការចោទប្រកាន់ ពាក់ព័ន្ធនឹងព្រឹត្តិការណ៍នៅស្ទឹងមានជ័យ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣។ វាជាការសំខាន់ដែលថា លោក វណ្ណី វ៉ាណន និងលោក មាស នុន ដែលជា សហជនជាប់ចោទ និងបុគ្គល ២៣ រូបទៀត ដែលត្រូវបានចោទប្រកាន់ទាក់ទងនឹងព្រឹត្តិការណ៍ថ្ងៃទី ២-៣ ខែមករា ទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងផ្អែកលើមូលដ្ឋាននៃភស្តុតាងជាក់ស្តែង។

ខ្ញុំចាប់អារម្មណ៍ជាខ្លាំង ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចរបស់ខ្ញុំទៅកាន់មណ្ឌលអប់រំកែប្រែ

ទី១ (CC1)។ ការអនុវត្តគោលនយោបាយកំណែទម្រង់ពន្ធនាគារ ដោយរដ្ឋាភិបាល បាននាំមកនូវភាពប្រសើរឡើងច្រើននៅក្នុងពន្ធនាគារ និងមណ្ឌលអប់រំកែប្រែនៅកម្ពុជា រួមទាំងការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌនៃការឃុំខ្លួន និងការប្រព្រឹត្តទៅលើជនជាប់ឃុំ និងការគ្រប់គ្រង និងរដ្ឋបាលពន្ធនាគារ។ បច្ចុប្បន្ននេះ ជនជាប់ឃុំ មានលទ្ធភាពទទួលបានប្រសើរជាងមុននូវទឹកស្អាត អនាម័យ និងខ្យល់អាកាស។

លើសពីនេះទៀត ខ្ញុំមានសេចក្តីរីករាយដោយមើលឃើញពីការរីកចម្រើន ដែលអគ្គនាយកដ្ឋានពន្ធនាគារសម្រេចបាន ក្នុងការពង្រឹងវិជ្ជាជីវៈរបស់បុគ្គលិកពន្ធនាគារ ធានាស្ថានភាពគតិយុត្តផ្សេងៗរបស់ពួកគេ និងរៀបចំឲ្យមាននូវកម្មវិធីបណ្តុះបណ្តាលយ៉ាងទូលំទូលាយ ដែលណែនាំពួកគេឲ្យយល់ដឹងអំពី បទដ្ឋានអន្តរជាតិទាក់ទងនឹងវិជ្ជាជីវៈរបស់ពួកគេ។ ខ្ញុំមានការពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការរបស់ពួកគេ ជាមួយនឹងកម្មវិធីកំណែទម្រង់ពន្ធនាគារនៃការិយាល័យ OHCHR ប្រចាំកម្ពុជា រួមទាំងការអនុញ្ញាតឲ្យចូលពិនិត្យពន្ធនាគារនានា ក៏ដូចជា កិច្ចសហប្រតិបត្តិការ របស់អាជ្ញាធរពន្ធនាគារ ជាមួយអង្គការមិនមែនរដ្ឋាភិបាល ក្នុងការផ្តល់ការកម្មវិធីទាក់ទងនឹងសុខភាព និងការស្តារនីតិសម្បទាដល់ពន្ធនាគារ ។

នៅមានបញ្ហាប្រឈមមួយចំនួន ក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់ពន្ធនាគារ។ អគ្គនាយកដ្ឋានពន្ធនាគារនៅខ្វះសមត្ថភាព ពន្ធនាគារនៅបន្តខ្វះបុគ្គលិក និងមានភាពចង្អៀតណែនដោយសារតែ អត្រាជនជាប់ឃុំក្នុងពន្ធនាគារថ្នាក់ជាតិមានជាង១៧០% និងនៅពន្ធនាគារមួយចំនួនមានអត្រាជនជាប់ឃុំជាង២០០% ។ ទោះជាយ៉ាងណា ខ្ញុំបានកត់សម្គាល់ ដោយការពេញចិត្តជាខ្លាំងអំពី កិច្ចសហប្រតិបត្តិការក្នុងស្មារតីស្ថាបនា ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ។ ខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាល សូមបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងការផ្តល់ធនធានគ្រប់គ្រាន់ដល់អគ្គនាយកដ្ឋានពន្ធនាគារ ដើម្បីអនុញ្ញាតឲ្យអគ្គនាយកដ្ឋាន អាចបំពេញភារកិច្ចរបស់ខ្លួនបាន ។

ការប្រព្រឹត្តដែលឈានទៅដល់ការធ្វើទារុណកម្ម និងការប្រព្រឹត្តបែបអមនុស្សធម៌ទៅលើអ្នកទោស និងជនជាប់ឃុំ គួរតែត្រូវបានតាមឃ្លាំមើល ដោយយន្តការបង្ការថ្នាក់ជាតិឯករាជ្យ )NPM) ដែលវាជាលក្ខខណ្ឌតម្រូវមួយ ក្រោមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម ដែលកម្ពុជាជារដ្ឋភាគី។ ខ្ញុំមានការសោកស្តាយ ដែលមិនមានវិធានការណាមួយឈានទៅដល់ការបង្កើតយន្តការដ៏សំខាន់មួយនេះ ដែលវាត្រូវបានប្រមើលឃើញរួចហើយនាពេលបច្ចុប្បន្ននេះ។ ខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាលឲ្យបង្កើតយន្តការបង្ការថ្នាក់ជាតិឯករាជ្យ )NPM)នេះឡើង ដោយគ្មានការពន្យាពេល។

## បញ្ហាដីធ្លី

ទាក់ទងទៅនឹងសិទ្ធិដីធ្លី ខ្ញុំសូមសរសើរដល់រដ្ឋាភិបាល ចំពោះវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការអនុវត្តការចុះបញ្ជីដីធ្លីជាប្រព័ន្ធ។ ប័ណ្ណកម្មសិទ្ធិដីធ្លី ប្រមាណជា ២.៦ លានប័ណ្ណ ត្រូវបានផ្តល់ជូនប្រជាពលរដ្ឋ ក្រោមកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ក្នុងអំឡុងពេលជាងមួយទសវត្សរ៍នេះ ។ នេះគឺជាសមិទ្ធផលដ៏សំខាន់មួយ។ វាច្បាស់ណាស់ថា ប្រទេសកម្ពុជានៅតែបន្តបោះជំហានដ៏សំខាន់ឆ្ពោះទៅមុខក្នុងការផ្តល់សុវត្ថិភាពខាងការកាន់កាប់ដីធ្លីដល់ប្រជាពលរដ្ឋទាំងអស់។

ក្នុងសប្តាហ៍នេះ ដោយបានចូលរួមក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិមួយ ស្តីពីសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច ខ្ញុំបានឮពីបុគ្គល គ្រួសារ និងសហគមន៍ ដែលត្រូវបានគេបណ្តេញចេញដោយបង្ខំពីដីធ្លីរបស់ពួកគេ ឬរស់នៅដោយការភ័យខ្លាចចំពោះសកម្មភាពបែបនេះ។ ទន្ទឹមនឹងការកោតសរសើរដល់និស្សិតស្ម័គ្រចិត្តរាប់រយនាក់ ដែលបានចូលរួមក្នុងក្នុងសម្មភាពបំរើប្រទេសជាតិ ដើម្បីវាស់វែងដីធ្លី ជូនគ្រួសារប្រជាពលរដ្ឋដែលរងហានិភ័យ ដែលនៅទីបំផុត បានដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិស្របច្បាប់នោះ ខ្ញុំបានកត់សំគាល់ដោយកង្វល់ផងដែរអំពីដំណើរការនៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីនេះបានផាត់ចេញដោយមិនមានការគិតគូរើពើដល់សហគមន៍ងាយរងគ្រោះមួយចំនួន។ ខ្ញុំសូមអំពាវនាវដល់អាជ្ញាធរឱ្យដាក់បញ្ចូលសហគមន៍ទាំងនោះនៅក្នុងដំណើរការនេះ និងពន្លឿនដំណើរការនៃការផ្តល់ប័ណ្ណកម្មសិទ្ធិនេះឲ្យបានឆាប់រហ័ស ដោយចាប់ផ្តើមពីការរៀបចំបង្កើតឲ្យមាននូវកម្រិតទទួលខុសត្រូវច្បាស់លាស់ក្នុងចំណោមក្រសួងនានា និងមូលដ្ឋានទិន្នន័យថ្នាក់ជាតិដ៏ទូលំទូលាយស្តីពីកម្មសិទ្ធិដីធ្លី ដែលអាចឲ្យសាធារណជនស្វែងរកព័ត៌មានបាន។ វិធានការជាក់លាក់ សំដៅជួយសម្រួលដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ក៏ការចាំបាច់ផងដែរ។

លទ្ធភាពទទួលបានព័ត៌មាន តម្លាភាព និងគណនេយ្យភាព ក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងការគ្រប់គ្រងដីសម្បទាន នៅតែជាក្តីបារម្ភជាដដែល។ សម្បទានដីសម្រាប់ចំការដំណាំ កសិ-ឧស្សាហកម្ម អាចធ្វើអន្តរាយដល់ជីវភាពរស់នៅបែបប្រពៃណីរបស់សហគមន៍នានាផងដែរ និងបានធ្វើឲ្យសហគមន៍ងាយរងគ្រោះ ត្រូវប្រឈមនឹងហានិភ័យនៃការបាត់បង់ដីធ្លី និងភាពក្រីក្រខ្លាំងឡើងថែមទៀត។ ការលើកកំពស់ការវិនិយោគវិស័យឯកជន មិនត្រូវធ្វើឲ្យខូចប្រយោជន៍របស់ប្រជាពលរដ្ឋមូលដ្ឋាន ឬមិនត្រូវផ្តល់អាទិភាពខ្ពស់ជាងលក្ខខណ្ឌតម្រូវផ្លូវច្បាប់ឡើយ គឺត្រូវគោរពសិទ្ធិជាមូលដ្ឋានរបស់ក្រុមជនជាតិដើមភាគតិច និងសមាជិកគ្រួសាររបស់ពួកគេ ។

កាលពីម្សិលមិញនេះ ខ្ញុំបានធ្វើទស្សនកិច្ចនៅកន្លែងតាំងទីលំនៅថ្មី នៃជនរងគ្រោះដោយការបណ្តេញចេញដោយបង្ខំ ដែលស្ថិតនៅឆ្ងាយដាច់ស្រយ៉ាល និងជាទីតាំងដែលមិនមានសកម្មភាពសេដ្ឋកិច្ចដែលអាចឲ្យប្រកបរបររកស៊ីចិញ្ចឹមជីវិតបាន។ ខ្ញុំត្រូវបានប្រាប់ឲ្យដឹងថា ស្ត្រីមួយចំនួននៅក្នុងសហគមន៍បានសម្រេចចិត្តកាត់សក់លក់ ដើម្បីយកប្រាក់ផ្គត់ផ្គង់គ្រួសារ ហើយអ្នកខ្លះប្រកបរបរជាអ្នករកស៊ីផ្លូវភេទ។

កាលពីដើមសប្តាហ៍នេះ ខ្ញុំបានជួបផងដែរ ជាមួយសហគមន៍ក្រីក្រមួយចំនួនរស់នៅក្នុងទីក្រុង ដែលបានរៀបរាប់ប្រាប់ខ្ញុំពីការដែលពួកគាត់ប្រយុទ្ធទាមទារយុត្តិធម៌ និងសិទ្ធិមានលំនៅដ្ឋានសមរម្យ ។ ខ្ញុំរំភើបចិត្តជាខ្លាំង ដោយឃើញពួកគាត់មានសេចក្តីក្លាហាន ព្រមទាំង កិច្ចខិតខំប្រឹងប្រែងរបស់អង្គការសង្គមស៊ីវិល ក្នុងការធ្វើឲ្យប្រសើរឡើង ដល់ជីវភាពរស់នៅរបស់គ្រួសារប្រជាពលរដ្ឋក្រីក្រនៅទីក្រុង។ ខ្ញុំស្នើយ៉ាងទទូចដល់រដ្ឋាភិបាល ឲ្យបន្តបង្កើត និងកំណត់ បទដ្ឋានអប្បបរមា និងការការពារផ្នែកនីតិវិធីលើការគ្រប់គ្រងការបណ្តេញចេញ និងការតាំងទីលំនៅថ្មី។ ស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមកន្លែងតាំងទីលំនៅថ្មី ត្រូវតែបំពេញតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ នៅក្នុងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលកម្ពុជាជារដ្ឋភាគី។

## អ្នកស្វែងរកសិទ្ធិជ្រកកោន

បញ្ហានៃការបញ្ជូន ឬការតាំងលំនៅជាថ្មីរបស់ ជនភៀសខ្លួន អ្នកស្វែងរកសិទ្ធិជ្រកកោន ឬទេសន្តរប្រវេសន៍ គឺជាប្រធានបទមួយ ក្នុងចំណោមប្រធានបទដទៃទៀត ដែលខ្ញុំបានពិភាក្សាជាមួយឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស។ ខ្ញុំចង់បង្ហាញពីចំណាប់អារម្មណ៍មួយដែលថា មតិយោបល់របស់ខ្ញុំនៅលើប្រធានបទនេះ គឺ តំណាងឲ្យការព្រមព្រៀងមួយរបស់អង្គការសហប្រជាជាតិស្តីពីការរៀបចំនេះនៅថ្ងៃអនាគត។ ដូចដែលខ្ញុំបាននិយាយ មានព័ត៌មានតិចតួចបំផុតដែលបានដឹងអំពីបញ្ហាជាក់លាក់នេះដែលអាចឲ្យធ្វើការបញ្ជាក់អះអាងបាន។ ទោះជាយ៉ាងណាក៏ដោយ មានសេចក្តីសម្រេចច្បាស់លាស់ជាអន្តរជាតិ ដែលត្រូវតែគោរពតាម។

បុគ្គលណាមួយ ដែលត្រូវបានបញ្ជូនមកប្រទេសកម្ពុជា ដោយមិនគិតពីស្ថានភាពគតិយុត្តរបស់ពួកគេទេ មានសិទ្ធិទទួលបានការការពារពីការមិនបញ្ជូនត្រឡប់ទៅប្រទេសដើមវិញ។ ខ្ញុំសូមកត់សំគាល់ផងដែរថា ប្រទេសកម្ពុជា ជាភាគីនៃអនុសញ្ញាស្តីពីសិទ្ធិជនភៀសខ្លួន ឆ្នាំ១៩៥១ ហើយក្នុងការទទួលយកអ្នកស្វែងរកសិទ្ធិជ្រកកោន ឬ ជនភៀសខ្លួន សម្រាប់ការតាំងលំនៅថ្មីនោះ កម្ពុជាត្រូវអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនចំពោះក្រុមមនុស្សទាំងនោះ ដែលរួមទាំងមានការបង្កើតនីតិវិធីសមស្រប

ដូចជាផ្តល់ឋានៈស្របច្បាប់អចិន្ត្រៃយ៍ ដល់ជនភៀសខ្លួន និងការបង្កើតឲ្យមានកម្មវិធីសមាហរណកម្មមួយដែលមានធនធានគ្រប់គ្រាន់ ដើម្បីធានាលទ្ធភាពទទួលបានសេវាសង្គម និងការងារធ្វើ។ ប្រទេសកម្ពុជា ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះបុគ្គលទាំងនេះ មិនថា ស្ថិតនៅក្រោមអនុសញ្ញាស្តីពីសិទ្ធិជនភៀសខ្លួន ឬស្ថិតនៅក្រោមលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិស្នូលដទៃទៀតឡើយ ។

ក្នុងការពិភាក្សារបស់ខ្ញុំ រដ្ឋាភិបាល បានអះអាងជាថ្មី ពីការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការលើកកម្ពស់បទដ្ឋានអន្តរជាតិ ហើយថា កិច្ចព្រមព្រៀងនេះ នឹងត្រូវអនុវត្តតែក្នុងលក្ខខណ្ឌនៃការទទួលយកដោយស្ម័គ្រចិត្តរបស់បុគ្គលពាក់ព័ន្ធតែប៉ុណ្ណោះ។

**សេចក្តីសន្និដ្ឋាន**

អ្នកទស្សនកិច្ចម្នាក់មកកាន់ប្រទេសកម្ពុជា មិនអាចមិនកត់សំគាល់ពីភាពរីកចម្រើនគួរឱ្យកត់សម្គាល់ផ្នែកសេដ្ឋកិច្ច ដែលកម្ពុជាសម្រេចបានក្នុងទិដ្ឋភាពជាច្រើន ហើយអាចថាជាប្រទេសផ្សេងមួយបើធៀបទៅនឹងពេលដែលខ្ញុំបានមកទស្សនកិច្ច កាលពីបួនឆ្នាំកន្លងទៅនេះ។ សមិទ្ធផលនេះ គួរតែត្រូវបានអបអរសាទរដោយសារថាកំណើនសេដ្ឋកិច្ចគួរតែអាចជួយពង្រឹងដល់ការការពារថែមទៀតដល់សិទ្ធិមនុស្ស ជាពិសេស សិទ្ធិសេដ្ឋកិច្ច និង សង្គមកិច្ច។

នៅក្នុងសប្តាហ៍នេះ ខ្ញុំបានជួបជាមួយបុគ្គលជាច្រើន ដែលទទួលផលពីការផ្លាស់ប្តូរទាំងនេះ ប៉ុន្តែក៏មានមនុស្សជាច្រើនទៀតដែរ ដែលកំពុងរំពឹងថាអត្ថប្រយោជន៍នេះនឹងធ្លាក់មកដល់ខ្លួនពួកគេ និងអ្នកផ្សេងទៀតដែលសម្រេចចិត្ត ដើម្បីក្លាយខ្លួនជាភ្នាក់ងារសម្រាប់ការផ្លាស់ប្តូរ។ ការសង្កត់ធ្ងន់លើសេដ្ឋកិច្ចរឹងមាំ គឺជាសង្គមមួយដែលខ្លាំងត្រៀមខ្លួនជាស្រេច ដើម្បីចូលរួមកសាងអនាគតរបស់ខ្លួន។ ខ្ញុំចាកចេញពីប្រទេសកម្ពុជានៅថ្ងៃនេះ ជាមួយនឹងការយល់ដឹងកាន់តែប្រសើរថែមទៀត អំពីបញ្ហាប្រឈមផ្សេងៗដែលកម្ពុជាកំពុងជួបប្រទះនាពេលបច្ចុប្បន្ននេះ ក៏ដូចជា ក្តីសង្ឃឹមថា ការរីកចំរើនសម្រាប់ទាំងអស់គ្នា គឺ អាចធ្វើទៅបាន។

ការិយាល័យ OHCHR រក្សាជំហរដដែល គឺការសន្យាធ្វើការរួមគ្នាជាមួយរដ្ឋាភិបាល និងប្រជាជនកម្ពុជា ឆ្ពោះទៅរកអនាគតនៃភាពរុងរឿង យុត្តិធម៌ និងការចូលរួមសម្រាប់ទាំងអស់គ្នានៅក្នុងប្រទេសនេះ។

សូមអរគុណចំពោះការយកចិត្តទុកដាក់របស់អ្នកទាំងអស់គ្នា។